# ក្រសួងប៉ូលីសទីក្រុងឡុងប៊ិច

## ចូរកាត់បន្ថយហានិភ័យរបស់អ្នកនៃការក្លាយទៅជា ជនរងគ្រោះនៃការលួចគាស់ផ្ទះ




## របៀបបង្ការការវាយចូល

- ត្រូវចាំថា សោដែលមិនចាក់មិនមែនជាសោទេ។ ជានិច្ចកាល ត្រូវចាក់សោទ្វារ និងបង្អួចរបស់អ្នក សូម្បីតែនៅពេលកំពុងតែចាកចេញរយៈពេលមួយនាទីក៏ដោយ។
- មិនត្រូវទុកឲ្យមានកំណត់សម្គាល់ដែលបញ្ជាក់ថា អ្នកមិននៅផ្ទះ ឬពេលណាដែលអ្នកនឹងត្រឡប់មកវិញឡើយ។
- ត្រូវស្គាល់ដោយខ្លួនអ្នកនូវមនុស្ស និងរថយន្តនានានៅក្នុងសង្កាត់របស់អ្នក។
- ប្រយ័ត្នប្រយែងចំពោះមនុស្សសង្ស័យដែលកំពុងគោះទ្វារ។ ពួកគេអាចជាចោរដ៏ធំម្នាក់ដែលកំពុងពិនិត្យមើលថាតើមានមនុស្សនៅផ្ទះ ឬក៏អត់។ សូមហៅទូរសព្ទសុំជំនួយប៉ូលីស បើអ្នកសង្ស័យលើមនុស្សម្នាក់ដែលមានការសំឡឹងមើលគួរឲ្យសង្ស័យ។
- ពិនិត្យមើលក្រុមការងារ និងអ្នកម៉ៅការទាំងអស់ឲ្យបានត្រឹមត្រូវ។
- មិនត្រូវឲ្យមានស្លាកឈ្មោះ ឬអត្តសញ្ញាណជាប់នឹងសោផ្ទះរបស់អ្នក ឬនៅមុខផ្ទះរបស់អ្នកទេ។ បើអ្នកធ្លាប់មានការបាត់បង់ ឬមានគេលួចវា អ្នកអាចនឹងមានភ្ញៀវដែលមិនចង់ជួបមកលេង។
- កុំទុកលាក់សោផ្ទះនៅខាងក្រៅផ្ទះរបស់អ្នក ទោះជានៅក្រោមកម្រាលជូតជើងមាត់ទ្វារ ក្នុង ឬក្រោមផើងផ្កា ក្រោមថ្ម ឬលើស្លាបព្រិលទ្វារក៏ដោយ។
- បិទទ្វារឲ្យជិត និងចាក់សោរោងឡានអ្នកឲ្យជាប់ នៅពេលដែលអ្នកមិននៅក្នុង ឬក្បែរៗនោះ។ ពួកចោរលួចអាចចូលរោងឡានចំហ និងយកចេញបាននូវកង់ ឧបករណ៍ និងរបស់របរថ្លៃៗផ្សេងៗទៀតក្នុងរយៈពេលតែពីរបីវិនាទីប៉ុណ្ណោះ (លឿនណាស់)។
- កាត់តម្រឹមដើមឈើ និងគម្ពោតរុកជាតិនានាដើម្បីកុំឲ្យវាបាំងមើលទៅក្នុងផ្ទះរបស់អ្នក ឬមើលចេញមកក្រៅមិនឃើញ។ ដើមឈើ និងគុម្ពឈើដែលលូតលាស់ខ្លាំងក៏អាចផ្តល់នូវការបិទបាំងឲ្យពពួកចោរលួចដែរ ហើយមែកឈើធំៗក៏បង្កើតបានជាជណ្តើរដ៏ធំសម្រាប់ពួកចោរលួចផងដែរ។
- ត្រូវធ្វើឲ្យប្រាកដថា លេខផ្ទះរបស់អ្នកអាចមើលឃើញទាំងយប់ទាំងថ្ងៃបាន។ លើសពីនេះ ដាក់វានៅខាងក្រោយរបងរបស់អ្នក បើអ្នកដីផ្ទះអ្នកនៅជិតទៅនឹងផ្លូវចង្អៀត ដោយសារថា ការធ្វើដូច្នេះនឹងជួយដល់ប៉ូលីសនៅក្នុងរកមើលទីលំនៅរបស់អ្នកបានក្នុងករណីមានអាសន្ន។



**ក្រសួងប៉ូលីសទីក្រុងឡុងប៊ិច**

**លេខសុំជំនួយបន្ទាន់នៃមជ្ឈមណ្ឌលទំនាក់ទំនងប៉ូលីស: 9-1-1**

**លេខមិនមែនជំនួយបន្ទាន់: 562-435-6711**

**ទីបញ្ជាការ: 562-570-7260**

**វិបសាយ: longbeach.gov/police**

- ការដាក់ភ្លើងបំភ្លឺគឺជាសញ្ញាកំញើញលេខមួយចំពោះបទឧក្រិដ្ឋ ដូច្នេះជានិច្ចកាលរៀបចំផ្ទះរបស់អ្នកឲ្យមានភ្លើងបំភ្លឺបានល្អ។
- ទុកឲ្យរានហាលមានបើកភ្លើងបំភ្លឺនៅពេលយប់ ឬពិចារណាលើការដាក់ឧបករណ៍សម្រាប់ចាប់យកចលនា ពន្លឺជាដើមដែលប្រើប្រព័ន្ធហ្វូតូសែល។ ឧបករណ៍សម្រាប់ចាប់យកចលនា ពន្លឺជាដើមនេះនឹងស្វ័យបើកអំពូលរបស់អ្នកក្បាលព្រលប់ និងបិទនៅពេលជិតភ្លឺ។
- ប្រើអង្គកំណត់ម៉ោងពេញក្នុងផ្ទះរបស់អ្នកនៅរាល់ពេលដែលអ្នកអាចនឹងមិននៅផ្ទះ។
- ចំណាយលើប្រព័ន្ធភេរវសញ្ញាចោរចូលលួច។ ប្រព័ន្ធភេរវសញ្ញាចោរចូលលួចដែលបន្ថែមទៅនឹងការចាក់សោគត់មត់ និងការបំភ្លឺត្រឹមត្រូវ ចូរបន្ថែមមធ្យោបាយជំនួយសន្តិសុខសុវត្ថិភាពដល់ផ្ទះរបស់អ្នក។
- ចាររបស់របរមានតម្លៃរបស់អ្នកដោយប្រើលេខប័ណ្ណបើកបរនៃរដ្ឋកាលីហ្វ័រញ៉ារបស់អ្នក។ ការធ្វើដូច្នេះធ្វើឲ្យអចលនទ្រព្យអ្នកកាន់តែពិបាកបញ្ចាំ និងជួយដល់ការអនុវត្តច្បាប់កំណត់ប្រភេទដីផ្ទះ (ក្នុងករណីមានការរកឃើញវិញ)។
- ត្រូវចាំថា បើអ្នកមកដល់ផ្ទះ ហើយពិនិត្យឃើញមានបង្អួចបាក់បែក ទ្វារបើក ឬភស្តុតាងបញ្ជាក់ថា មានមនុស្សបានលួចក្នុងផ្ទះរបស់អ្នក **កុំចូលទៅក្នុងផ្ទះ!** ទូរសព្ទហៅប៉ូលីសជាបន្ទាន់!

បើអ្នកឃើញហេតុការណ៍នៃសកម្មភាពសង្ស័យ សូមមេត្តាទៅទូរសព្ទទៅក្រសួងប៉ូលិស (នគរបាល) ជាបន្ទាន់។ នៅខណៈដែលសកម្មភាពសង្ស័យមួយចំនួនអាចនឹងមានបំណកស្រាយពន្យល់ហួសពីការសង្ស័យ ក្រសួងប៉ូលិសបែបនឹងស៊ើបអង្កេតផងដែរនូវស្ថានភាពមួយ ហើយប្រហែលជារាំងខ្ទប់នូវបទឧក្រិដ្ឋមួយទៀតផងដែរ ជំនួសការឲ្យគេហៅ នៅពេលដែលវានឹងយឺតការណ៍។ អ្នកជិតខាងរបស់អ្នកនឹងវាយតម្លៃខ្ពស់ចំពោះវា!